ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៣២ សហវ. ប្រ.ក. ២០២៤

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផ្តល់សេវាសាធារណៈសម្រាប់ការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត

### ឧបនាយករដ្ឋមន្ត្រី

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ១១០ អនក្រ.បក ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ២៨៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត
- បានឃើញប្រកាសរួមលេខ៤៩៨ សហវ.ប្រក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញប្រកាសរួមលេខ៤៩៩ សហវ.ប្រក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយនិយ័តករទូរគមនាគមន៍កម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ការផ្តល់សេវាសាធារណៈសម្រាប់ការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត ដែលកំណត់ដោយប្រកាសអន្តរក្រសួងនេះ សំដៅត្រឹមឈ្មោះដែនជាតិដែលមានទម្រង់ .kh, .com.kh, .org.kh, .edu.kh, .net.kh និង .gov.kh ប៉ុណ្ណោះ មិនរួមបញ្ចូលឈ្មោះដែនជាតិដែលមានទម្រង់ .ខ្មែរ ដែលនឹងកំណត់ដោយប្រកាសអន្តរក្រសួងដោយឡែក។

**ប្រការ២ .-**

សេវាសាធារណៈដែលផ្តល់ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សម្រាប់ការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលបរិយាយអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពនៃសេវាទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៣ .-**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាស្ថាប័នមានសមត្ថកិច្ចលើការគ្រប់គ្រងឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត។

និយ័តករទូរគមនាគមន៍កម្ពុជា បំពេញមុខងារជាសេនាធិការឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លើការផ្តល់សេវាសាធារណៈ សម្រាប់ការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត។

**ប្រការ៤ ._**

លក្ខខណ្ឌ បែបបទ និងនីតិវិធី នៃការផ្តល់សេវាសាធារណៈ សម្រាប់ការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ៥ ._**

ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត ត្រូវកត់ត្រាជាចំណូលរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ៦ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ ._**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងនិយ័តករទូរគមនាគមន៍កម្ពុជា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងលេខ៣៣៦សហវ.ប្រក.អទច ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការផ្តល់សេវាសាធារណៈសម្រាប់ការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត

## កម្រងសេវាសាធារណៈសម្រាប់ការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត

| លេខរៀង ចំនួនសេវា | | បរិយាយ | តម្លៃសេវា | | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|---|
| | | | ឯកតាគិត | ទឹកប្រាក់ (រៀល) | | |
| | I. | **ការផ្តល់សេវាប្រើប្រាស់ឈ្មោះដែនជាតិកម្រិតទី១ ដែលមានទម្រង់ .kh** | | | | |
| | ១- | ការចុះឈ្មោះប្រើប្រាស់លើកដំបូង | | | | |
| ១ | | - ចុះឈ្មោះដែនជាតិដែលមាន១(មួយ)តួ | គេហទំព័រ | ១២.០០០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ២ | | - ចុះឈ្មោះដែនជាតិដែលមាន២(ពីរ)តួ | គេហទំព័រ | ៦.០០០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ៣ | | - ចុះឈ្មោះដែនជាតិដែលមាន៣(បី)តួ | គេហទំព័រ | ៣.០០០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ៤ | | - ចុះឈ្មោះដែនជាតិដែលមានចាប់ពី៤(បួន)តួឡើងទៅ | គេហទំព័រ | ១៦០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| | ២- | ការបន្តសុពលភាពប្រើប្រាស់ | | | | |
| ៥ | | - បន្តសុពលភាពឈ្មោះដែនជាតិដែលមាន១(មួយ)តួ | គេហទំព័រ | ៣២០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ៦ | | - បន្តសុពលភាពឈ្មោះដែនជាតិដែលមាន២(ពីរ)តួ | គេហទំព័រ | ៣២០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ៧ | | - បន្តសុពលភាពឈ្មោះដែនជាតិដែលមាន៣(បី)តួ | គេហទំព័រ | ៣២០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ៨ | | - បន្តសុពលភាពឈ្មោះដែនជាតិដែលមានចាប់ពី៤(បួន)តួឡើងទៅ | គេហទំព័រ | ១៦០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |

| លេខរៀង ចំនួនសេវា | បរិយាយ | | តម្លៃសេវា | | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|---|
| | | | ឯកតាគិត | ទឹកប្រាក់ (រៀល) | | |
| | II. | **ការផ្តល់សេវាប្រើប្រាស់ឈ្មោះដែនជាតិកម្រិតទី២ ដែលមានទម្រង់** .com.kh, .org.kh, .edu.kh **និង** .net.kh | | | | |
| | ១- | ការចុះឈ្មោះប្រើប្រាស់លើកដំបូង | | | | |
| ៩ | | - ចុះឈ្មោះដែនជាតិដែលមាន១(មួយ)តួ | គេហទំព័រ | ១២.០០០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ១០ | | - ចុះឈ្មោះដែនជាតិដែលមាន២(ពីរ)តួ | គេហទំព័រ | ៦.០០០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ១១ | | - ចុះឈ្មោះដែនជាតិដែលមាន៣(បី)តួ | គេហទំព័រ | ៣.០០០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ១២ | | - ចុះឈ្មោះដែនជាតិដែលមានចាប់ពី៤(បួន)តួឡើងទៅ | គេហទំព័រ | ១២០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| | ២- | ការបន្តសុពលភាពប្រើប្រាស់ | | | | |
| ១៣ | | - បន្តសុពលភាពឈ្មោះដែនជាតិដែលមាន១(មួយ)តួ | គេហទំព័រ | ៣២០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ១៤ | | - បន្តសុពលភាពឈ្មោះដែនជាតិដែលមាន២(ពីរ)តួ | គេហទំព័រ | ៣២០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ១៥ | | - បន្តសុពលភាពឈ្មោះដែនជាតិដែលមាន៣(បី)តួ | គេហទំព័រ | ៣២០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| ១៦ | | - បន្តសុពលភាពឈ្មោះដែនជាតិដែលមានចាប់ពី៤(បួន)តួឡើងទៅ | គេហទំព័រ | ១២០.០០០ | ៣ថ្ងៃ | ០១ឆ្នាំ |
| | III. | **ការផ្តល់សេវាប្រើប្រាស់ឈ្មោះដែនជាតិកម្រិតទី២ ដែលមានទម្រង់** .gov.kh | | | | |
| ១៧ | | - ចុះឈ្មោះប្រើប្រាស់លើកដំបូង | គេហទំព័រ | មិនគិតថ្លៃ | ៣ថ្ងៃ | ០១ឆ្នាំ |
| ១៨ | | - បន្តសុពលភាពប្រើប្រាស់ | គេហទំព័រ | មិនគិតថ្លៃ | ៣ថ្ងៃ | ០១ឆ្នាំ |

| លេខរៀង | ចំនួនសេវា | បរិយាយ | តម្លៃសេវា | | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|---|
| | | | ឯកតាគិត | ទឹកប្រាក់ (រៀល) | | |
| | IV. | **ការផ្តល់សេវាផ្សេងៗទៀត ពាក់ព័ន្ធនឹងការប្រើប្រាស់ឈ្មោះដែនជាតិកម្រិតទី១ និងកម្រិតទី២** | | | | |
| ១៩ | | - ពិនិត្យសំណើសុំចុះឈ្មោះដែនជាតិ | គេហទំព័រ | មិនគិតថ្លៃ | ៣ថ្ងៃ | ០១លើក |
| ២០ | | - ផ្លាស់ប្តូរព័ត៌មានឈ្មោះដែនជាតិ | គេហទំព័រ | មិនគិតថ្លៃ | ១០ថ្ងៃ | ០១លើក |
| ២១ | | - ផ្លាស់ប្តូរ Name Server និង IP Address ឈ្មោះដែនជាតិ | គេហទំព័រ | មិនគិតថ្លៃ | ១០ថ្ងៃ | ០១លើក |
| ២២ | | - ភ្ជាប់ការប្រើប្រាស់ឈ្មោះដែនជាតិឡើងវិញ | គេហទំព័រ | មិនគិតថ្លៃ | ១០ថ្ងៃ | ០១លើក |
| ២៣ | | - ការផ្ទេរឈ្មោះដែនជាតិកម្រិតទី១ ដែលមានទម្រង់ .kh | គេហទំព័រ | ១៦០.០០០ | ១០ថ្ងៃ | ០១លើក |
| ២៤ | | - ការផ្ទេរឈ្មោះដែនជាតិកម្រិតទី២ ដែលមានទម្រង់ .com.kh, .org.kh, .edu.kh និង .net.kh | គេហទំព័រ | ១៦០.០០០ | ១០ថ្ងៃ | ០១លើក |
| ២៥ | | - ការលុបឈ្មោះដែនជាតិ ដែលឈប់ប្រើប្រាស់ | គេហទំព័រ | មិនគិតថ្លៃ | ៣ថ្ងៃ | ០១លើក |

សម្គាល់÷ ពាក្យ ត្ន ដែលប្រើក្នុងកម្រងសេវាសាធារណៈនេះ សំដៅដល់ចំនួននៃព្យញ្ជនៈ ស្រៈ លេខ ឬសហសញ្ញា ដែលកំណត់ដោយអនុក្រឹត្យលេខ ២៨៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត។